ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚ * ៛

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំសម្របសម្រួលជាមួយក្រុមបុរសស្រឡាញ់បុរស

## ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១

## នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## វេលាម៉ោង: ៨:០០

**១.គោលបំណង**

- ពិនិត្យ និងពិភាក្សានូវឧបសគ្គមួយចំនួនដែលរាំងដល់បទអន្តរាគមន៍បង្ការនៃមេរោគអេដស៍ ជំងឺអេដស៍ និងផលប៉ះពាល់ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស នៅរាជធានីភ្នំពេញ។

**២.កាលបរិច្ឆេទ និងទីកន្លែង**

- កាលបរិច្ឆេទៈថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១១។
- ទីកន្លែងៈ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៣.វិធីសាស្ត្រ**

- ជួបប្រជុំជាមួយក្រុមបុរសស្រឡាញ់បុរសនៅរាជធានីភ្នំពេញ។

**៤.លទ្ធផល**

កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមបុរសស្រឡាញ់បុរសនៅរាជធានីភ្នំពេញសរុបប្រមាណ៤៥នាក់ ដែលមកពីក្រុមគោលដៅក្នុងខ័ណ្ឌទាំងប្រាំបី រួមមាន ខ័ណ្ឌមានជ័យ ខ័ណ្ឌចំការមន ខ័ណ្ឌ៧មករា ខ័ណ្ឌដូនពេញ ខ័ណ្ឌទួលគោក ខ័ណ្ឌដង្កោ ខ័ណ្ឌបស្សីកែវ និងខ័ណ្ឌសែនសុខ ។ អញ្ជើញចូលរួមដោយ គណៈអធិបតីក្នុងអង្គប្រជុំ រួមមាន ឯកឧត្តម តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេស ថ្នាក់ជាតិបុរសស្រឡាញ់បុរស លោកវេជ្ជ.លី ពេញស៊ុន អនុប្រធានមជ្ឈមណ្ឌលជំងឺកាមរោគ និងសើស្បែក លោកវេជ្ជបណ្ឌិត រស់ សីលវ៉ាត់ អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លោកសៅ សុភាព តំណាងក្រុមបុរសស្រឡាញ់បុរសប្រទេសកម្ពុជា លោកទីម វ៉ា តំណាងសង្គមស៊ីវិល និងអស់លោកជាសមាជិកលេខាធិការដ្ឋានក្រុមបុរសស្រឡាញ់បុរស ។ជាដំបូង ឯកឧត្តម តែង គន្ធី អគ្គលេខាធិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេស ថ្នាក់ជាតិបុរសស្រឡាញ់បុរស បានស្វាគមន៍

និងអរគុណយ៉ាងជ្រាវជ្រៅចំពោះវត្តមានដ៏មានសារៈសំខាន់របស់បុរសស្រឡាញ់បុរសដែលជាសកម្មជន ក្នុងការឆ្លើយតបទៅនឹងបទអន្តរាគមន៍បង្ការការរីករាលដាលមេរោគ និងជំងឺអេដស៍ ។ ប្រធានបទសំខាន់ដែលលើកយកមកពិភាក្សាថ្ងៃនេះគឺបញ្ហាស្រោមអនាម័យ និងទឹករំអិល ។តាមការស្តាប់ការរាយការណ៍របស់ក្រុមគោលដៅនៅតាមខ័ណ្ឌនីមួយៗ អង្គប្រជុំបានរកឃើញថាបញ្ហាចំបងនោះគឺការខ្វះស្រោមអនាម័យនៅតាមចំនុចគោលដៅដែលក្រុមបុរសស្រឡាញ់បុរសធ្វើការចាប់តាំងពីខែកក្កដា ២០១១ មកម្លេះ។ តាមរយៈនៃ អង្គប្រជុំ ឯកឧត្តមប្រធានបាន ឱ្យអនុសាសន៍ថា មធ្យោបាយដ៏ល្អនៅពេលនេះប្អូនៗគួរតែទិញស្រោមអនាម័យ ដើម្បីសុវត្ថិភាព ផ្ទាល់ខ្លួនប្អូន។ បន្ទាប់មកត្រូវធ្វើរបាយការណ៍ លំអិតនៅតាមខ័ណ ពីបញ្ហាកង្វះស្រោមអនាម័យដាក់មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីសំរបសំរួលស្នើរសុំជាបណ្តោះអាសន្នពីPSI ។

បញ្ហាទូទៅឯកឧត្តមបានសង្កត់ធ្ងន់ថាចំពោះប្រព័ន្ធផ្សព្វផ្សាយ ត្រូវពិនិត្យ លទ្ធភាព និងរៀបចំឯកសារឱ្យអ្នកសារពត៌មានក្នុងការផ្សព្វផ្សាយជាសាធារណៈ ។ក្រុមបុរសស្រឡាញ់បុរស គួរតែមានវគ្គ បណ្តុះបណ្តាលអប់រំសីលធម៌ និងសុជីវធម៌ និងរក្សាសេចក្តីថ្លៃថ្នូក្នុងសង្គម និងឈានទៅដល់ការអប់រំជាទូទៅ ។ក្នុងយុទ្ធនាការបទអន្តរាគមន៍បង្ការការរីករាលដាលមេរោគ និងជំងឺអេដស៍ទៅលើក្រុមបុរសស្រឡាញ់បុរស ឱកាសបុណ្យអុំទូក ដោយធ្វើសកម្មភាព អប់រំដល់ក្រុមគោលដៅ ។

ជាទីបញ្ចប់ ឯកឧត្តម អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងអំណរគុណនិងកើតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមបុរសស្រឡាញ់បុរសរាជធានីភ្នំពេញ ដែលជាសកម្មជនបាន សហការគ្នាល្អធ្វើឱ្យការងារឆ្លើយតបទៅការ ទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ទទួលលទ្ធផល គួរឱ្យកោតសរសើរទោះបីមានជួបបញ្ហា មួយចំនួនក៏ដោយ ។

ភ្នំពេញថ្ងៃទី ២០ខែតុលា ឆ្នាំ ២០១១

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| **អគ្គលេខាធិការ** | ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ | |
| **វេជ្ជ. តែង គន្ធី** | | |